Washington State Department of Social & Health Services

ផែនការទទួលខុសត្រូវនៃបុគ្គល (IRP)

INDIVIDUAL RESPONSIBILITY PLAN (IRP)

ផែនការទទួលខុសត្រូវនៃឯកត្តជនក្នុងកម្មវិធី WorkFirst សំរាប់

JAS ID
CASE NUMBER
CLIENT ID

ខ្ញុំយល់ថា:

- ខ្ញុំត្រូវតែសហប្រតិបត្តិការណ៍ជាមួយនាយកដ្ឋានឧបត្ថម្ភក្មេងនៅពេលដែលខ្ញុំទទួលជំនួយពីកម្មវិធី TANF/SFA លើកលែងតែខ្ញុំមានមូលហេតុល្អក្នុងការមិនធ្វើសហប្រតិបត្តិការណ៍ ។ ការប្រមូលប្រាក់ឧបត្ថម្ភក្មេងយ៉ាងដោតជ័យអាចជួយខ្ញុំបំបាត់សេចក្តីត្រូវការជំនួយប្រាក់របស់ខ្ញុំ ។
- ខ្ញុំអាចទទួលជំនួយតែ 60 ខែប៉ុណ្ណោះសំរាប់ជំនួយប្រាក់កម្មវិធី TANF/SFA ក្នុងមួយជីវិតរបស់ខ្ញុំ លើកលែងតែខ្ញុំមានគុណសម្បត្តិសំរាប់ការពន្យាពេល ។
- ខ្ញុំបានប្រើកម្មវិធីជំនួយប្រាក់ចំនួន _____ ខែហើយ ។
- ខ្ញុំបានត្រូវគំរូវឲ្យទៅធ្វើការ, រកការងារធ្វើ, ឬប្រុងប្រៃបធ្វើការពេញម៉ោង យ៉ាងហោចណាស់បាន 32 ម៉ោងក្នុងមួយអាទិត្យ ។
- បើសិនជាខ្ញុំមិនអាចទៅចូលរួមក្នុងសកម្មភាពដែលបានកំណត់ទុកពីមុន ខ្ញុំនឹងទូរស័ព្ទទៅម្នាក់តាមលេខទូរស័ព្ទដែលមានរាយនៅខាងក្រោម ។
- ខ្ញុំត្រូវតែធ្វើនូវសកម្មភាពដូចតទៅនេះ សំរាប់ពេលមួយចំនួនរៀងរាល់អាទិត្យ ដែលបានបញ្ជាក់ប្រាប់នៅខាងក្រោមនេះ:

XB – ការដាក់ពាក្យសំរាប់ជំនួយដទៃទៀត

ចាប់ពីថ្ងៃទី _____ ទៅដល់ _____, ខ្ញុំយល់ព្រមដើម្បីចូលរួមចំនួន _____ ម៉ោងក្នុងមួយអាទិត្យ ជាមួយអ្នកផ្តល់ការបំរើដែល មានរាយឈ្មោះនៅខាងក្រោម ក្នុងការស្វែងរកប្រាក់ជំនួយដទៃទៀត ដូចជា SSI, L&I, និង VA ជាដើម ។

នាយកគ្រប់គ្រងសំណុំរឿងរបស់ខ្ញុំ ហើយនិងខ្ញុំនឹងពិនិត្យផែនការ IRP នេះជាថ្មីឡើងវិញនៅមុនថ្ងៃទី _____។

អ្នកផ្តល់ការបំរើ/ការិយាល័យ : _____

អាសយដ្ឋាន : _____

ឈ្មោះអ្នកដែលអាចទាក់ទងបាន : _____

លេខទូរស័ព្ទអ្នកដែលអាចទាក់ទងបាន : _____

ខ្ញុំនឹងមានវត្តមានគ្រប់ពេលកំណត់ការណាត់ជួបនិងសវនាការទាំងអស់, បំពេញគ្រប់ការគំរូវក្រដាសពាក្យ, ផ្តល់ឲ្យគ្រប់ការគំរូវនូវឯកសារ, ហើយនិងចូលរួមឲ្យអស់ពីសមត្ថភាពរបស់ខ្ញុំ ។ ខ្ញុំនឹងរក្សាផ្តល់គ្រប់ពត៌មានទៅឲ្យនាយកគ្រប់គ្រងសំណុំរឿង WorkFirst /អ្នកធ្វើការផ្នែកសង្គមកិច្ចនូវទំនាក់ទំនងនានា ដែលខ្ញុំទទួលពីទីភ្នាក់ងារ ដទៃទៀត ដោយរួមទាំងការិយាល័យនិរភ័យសង្គមកិច្ច, L&I, VA និងក្រដាសស្នាមមកពីមេធាវីដែលកាន់ការាប់សំណុំរឿងទាមទាររបស់ខ្ញុំ ។

ខ្ញុំមានសេវាមើលថែទាំកូននិងការដឹកនាំគ្រប់គ្រាន់ ដែលបានលើកយកមកនិយាយ ។

បើសិនជាខ្ញុំមិនអាចមានវត្តមានចំពោះការណាត់ជួបឬសវនាការណាមួយបាន, ឬមិនអាចបំពេញក្រដាសកិច្ចការឲ្យទាន់ថ្ងៃកំណត់ដែលបានចាត់តាំងបាន ខ្ញុំនឹងទូរស័ព្ទទៅជនដែលអាចទាក់ទងបាន តាមលេខដែលមានរាយនៅខាងលើ ក្នុងថ្ងៃដដែលនោះឬមុនថ្ងៃនោះ ហើយពន្យល់ពីហេតុដែលខ្ញុំមិនអាចមក ឬមិនបានបំពេញក្រដាសកិច្ចការ ។

ខ្ញុំយល់ថា បើសិនជាខ្ញុំមិនទូរស័ព្ទមកនៅថ្ងៃដដែលនោះឬមុនថ្ងៃនោះទេ វានឹងត្រូវបានគេចាត់ទុកថា ឈប់ដោយឥតច្បាប់ ហើយអាចបណ្តាលឲ្យមានការដាក់ទណ្ឌកម្ម ។

បើសិនជាមានមូលហេតុល្អ ខ្ញុំមិនអាចធ្វើតាមផែនការខ្ញុំទេ ខ្ញុំត្រូវទាក់ទងនិងធ្វើការជាមួយអ្នកឯកទេសកម្មវិធី WorkFirst/អ្នកធ្វើការផ្នែកសង្គមកិច្ចយ៉ាងឆាប់បំផុតដែលអាចធ្វើទៅបាន ។ ឧទាហរណ៍ខ្លះៗនៃមូលហេតុល្អមានរួមទាំង: • ខ្ញុំមិនបានទៅចូលរួមតាមការណាត់ជួប ដោយសារតែមានជម្លី ឬគ្មានអ្នកថែទាំកូនរបស់ខ្ញុំឬគ្មានយានជំនិះដោយចៃដន្យ; • ខ្ញុំមានស្ថានភាពបន្ទាន់អាសន្នផ្នែក (ទូវរាងកាយ, ផ្លូវចិត្តឬផ្លូវអារម្មណ៍, ឬការរំជួលចិត្តចង់បានអ្វីមួយ); • ខ្ញុំជាអ្នករងគ្រោះនៃគ្រួសារហិង្សា; • ខ្ញុំមិនអាចរកអ្នកថែកូនដែលមានតំលៃថោក, សមរម្យគ្រឹមត្រូវនៅក្នុងតំបន់ខ្ញុំសំរាប់ក្មេងដែលមានអាយុក្រោម 13 ឆ្នាំ; • ខ្ញុំមានបញ្ហាផ្នែកច្បាប់ដែលត្រូវការបន្ទាន់; • ខ្ញុំមានពិការភាព ឬជម្លីមួយចំនួន ហើយបញ្ហានេះរារាំងខ្ញុំមិនអាចឲ្យខ្ញុំបំពេញបំណងតាមសេចក្ដីតំរូវរបស់កម្មវិធីបាន; ឬ • ខ្ញុំជាមនុស្សពេញវ័យដែលមានពិការភាពធ្ងន់ធ្ងរនិងរាំរៃ; • ខ្ញុំត្រូវការអ្នកថែទាំក្មេងតាមផ្ទះសំរាប់កូនដែលមានសេចក្ដីត្រូវការពិសេស ឬមនុស្សពេញវ័យផ្សេងទៀតដែលមានពិការភាព; • ខ្ញុំមានអាយុ 55 ឆ្នាំ ឬចាស់ជាង និងកំពុងថែទាំក្មេង ហើយខ្ញុំមិនមែនជាឪពុកឬម្ដាយរបស់ក្មេងនោះទេ; ឬ • ខ្ញុំដាក់ពាក្យសុំជំនួយ SSI ពីអ្នកសំរួលការនៃក្រសួង DSHS ។ បើសិនជាខ្ញុំមិនយល់ស្របតាមផែនការនេះទេ ខ្ញុំមានសិទ្ធិស្នើសុំធ្វើការពិនិត្យឡើងវិញ និង/ឬស្នើសុំធ្វើសវនាការ ។ ដើម្បីស្នើសុំធ្វើសវនាការ ខ្ញុំត្រូវតែទាក់ទងទៅការិយាល័យផ្នែកសេវាសហគមន៍ ឬទៅការិយាល័យផ្នែកសវនាការរដ្ឋបាល Office of Administrative Hearings, DSHS, PO Box 42488, Olympia WA 98504-2488, នៅក្នុងរវាង 90 ថ្ងៃចាប់តាំងពីថ្ងៃដែលអ្នកចាត់ការសំណុំរឿងរបស់ខ្ញុំបានចុះហត្ថលេខានៅខាងក្រោមនេះ ។ គេបានឲ្យក្រដាសចម្លងផែនការទទួលខុសត្រូវដាងកត្តជនដល់ខ្ញុំមួយច្បាប់ ។			
ហត្ថលេខារបស់អ្នកចាត់ការសំណុំរឿង	ខែ/ថ្ងៃ/ឆ្នាំ	ហត្ថលេខារបស់ខ្ញុំ	ខែ/ថ្ងៃ/ឆ្នាំ

JAS ID	CASE NUMBER	CLIENT ID

ការតំរូវភាពលាក់ការ

ខ្ញុំប្រហែលអាចត្រូវទទួលសេវាឧបត្ថម្ភដើម្បីជួយខ្ញុំឲ្យមានភាពចំរើនចំពោះការងាររបស់ខ្ញុំ, រក្សាការងាររបស់ខ្ញុំ, ទទួលធ្វើការងារ, រកការងារធ្វើ, ឬធ្វើតាមផែនការរបស់ខ្ញុំ ។ បើសិនជាខ្ញុំមិនយល់ស្របតាមសេចក្តីសំរេចអំពីសេវាឧបត្ថម្ភ ខ្ញុំអាចស្នើសុំការពិនិត្យសំណុំរឿងឡើងវិញ និង/ឬស្នើសុំធ្វើសវនាការ ។ ខ្ញុំនឹងស្នើសុំទៅអ្នកឯកទេសកម្មវិធី WorkFirst/អ្នកធ្វើការផ្នែកសង្គមកិច្ច បើសិនជាខ្ញុំត្រូវការសេវាឧបត្ថម្ភដូចជា:

- ផ្ទះសណ្ដូលឡាន
- កន្ទបទារក
- សំបុត្របើកបរ/ថ្លៃឈ្នួល
- ថ្លៃសាំង
- សំលៀកបំពាក់
- បង់ថ្លៃសាលា
- កាត់សក់
- ឧបករណ៍ទៅធ្វើការ
- ការឲ្យឱ្យវាទ
- ប្រដាប់អនាម័យផ្ទាល់ខ្លួន
- សំបុត្ររថយន្តក្រុង
- ផែនការគ្រួសារ

ខ្ញុំដឹងថា ខ្ញុំត្រូវតែធ្វើសកម្មភាពតាមការតំរូវ ។ បើសិនជាខ្ញុំមិនធ្វើតាម ខ្ញុំនឹងទទួលការពិន័យ លើកលែងតែខ្ញុំអាចបញ្ជាក់ថាខ្ញុំមានមូលហេតុល្អ ។ ការនេះគឺហៅថា ស្ថានភាពទណ្ឌកម្មនៅក្នុងផែនការ WorkFirst ។ បើសិនជាខ្ញុំបានទទួលទណ្ឌកម្ម គឺមានន័យថា:

- ជំនួយរបស់ខ្ញុំនិងត្រូវកាត់បន្ថយចំនួន 40 ភាគរយឬចំណែកជំនួយម្នាក់ យកមួយណាដែលធំជាង ។
- ខ្ញុំត្រូវតែធ្វើតាមផែនការ IRP របស់ខ្ញុំសំរាប់រយៈពេលបួនអាទិត្យជាប់ៗគ្នា ដើម្បីឲ្យរួចពីការទទួលទណ្ឌកម្ម ។
- នៅពេលណាដែលខ្ញុំធ្វើនូវអ្វីដែលបានតំរូវរួចសំរាប់បួនអាទិត្យជាប់ៗគ្នារួចហើយ ការពិន័យលើទណ្ឌកម្មរបស់ខ្ញុំនឹងត្រូវលើកលែងចាប់តាំងពីថ្ងៃទីមួយនៃខែបន្ទាប់ បន្ទាប់ពីការចូលរួមចំនួនបួនអាទិត្យរបស់ខ្ញុំ ។
- ក្រុមផ្នែកពិនិត្យទណ្ឌកម្មនឹងពិនិត្យឡើងវិញ ហើយអាចបិទ សំណុំរឿងរបស់ខ្ញុំ បើសិនជាខ្ញុំនៅក្នុងទណ្ឌកម្មសំរាប់រយៈពេលប្រាំមួយខែជាប់បន្តៗគ្នា ។
  - បើសំណុំរឿងរបស់ខ្ញុំបានបិទដោយសារក្រុមផ្នែកពិនិត្យទណ្ឌកម្មឡើងវិញ ខ្ញុំនឹងត្រូវដាក់ពាក្យសុំជាថ្មីឡើងវិញ ហើយចូលរួមសំរាប់បួនអាទិត្យជាប់បន្តៗគ្នា មុននឹងខ្ញុំអាចទទួលប្រាក់ជំនួយវិញ ។
  - បើសិនជាសំណុំរឿងរបស់ខ្ញុំបានទទួលទណ្ឌកម្មជាថ្មីឡើងវិញ ក្រុមប្រឹក្សាផ្នែកពិនិត្យទណ្ឌកម្មនឹងពិនិត្យឡើងវិញ ហើយអាចបិទ សំណុំរឿងរបស់ខ្ញុំ បើសិនជាខ្ញុំនៅក្នុងទណ្ឌកម្មសំរាប់រយៈពេលបីខែជាប់បន្តៗគ្នា ។

នៅពេលដែលខ្ញុំទទួលទណ្ឌកម្ម ខ្ញុំមិនអាចទទួលសេវាឧបត្ថម្ភបានទេ (ដូចជាប្រាក់សំរាប់ទីញខោអាវទៅធ្វើការ ឬសំរាប់ធ្វើដំណើរ) រហូតដល់ពេលខ្ញុំចាប់ផ្តើមធ្វើកម្មវិធី IRP របស់ខ្ញុំបន្តទៅទៀត ។

ខ្ញុំដឹងថា បើសិនជាខ្ញុំបដិសេធចូលធ្វើសហប្រតិបត្តិការជាមួយនាយកដ្ឋានឧបត្ថម្ភក្មេង (DCS) ដោយគ្មានមូលហេតុល្អ នោះជំនួយប្រាក់របស់ខ្ញុំអាចត្រូវកាត់បន្ថយ ។ មូលហេតុល្អមានរួមទាំង ការគំរាមកំហែងធ្វើឲ្យមានគ្រោះថ្នាក់រាងកាយដល់កូនខ្ញុំទាំងអស់ឬរូបខ្ញុំ ។ ខ្ញុំដឹងថា នៅពេលដែលខ្ញុំទទួលជំនួយប្រាក់ TANF ប្រាក់ឧបត្ថម្ភក្មេងណាដែលខ្ញុំប្រមូលបាន គឺត្រូវបង់សងទៅរដ្ឋវិញទាំងអស់ ។

នៅពេលណាខ្ញុំឈប់ទទួលជំនួយ TANF/SFA, នាយកដ្ឋាន DCS នឹងប្រមូលប្រាក់ឧបត្ថម្ភក្មេងហើយផ្ញើមកឲ្យខ្ញុំវិញ លើកលែងតែខ្ញុំជំរាបទៅគេឲ្យឈប់ផ្ញើមក ។ ខ្ញុំដឹងអំពីសេវាឧបត្ថម្ភ, ការទទួលទណ្ឌកម្ម, និង ការឧបត្ថម្ភក្មេង ។

ហត្ថលេខារបស់នាយកគ្រប់គ្រងសំណុំរឿង	ខែ/ថ្ងៃ/ឆ្នាំ	ហត្ថលេខារបស់ខ្ញុំ	ខែ/ថ្ងៃ/ឆ្នាំ